ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

របាយការណ៍
កិច្ចប្រជុំរួមប្រចាំខែកក្កដា ឆ្នាំ២០២១
របស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅព្រឹកថ្ងៃអង្គារ ១០រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ចាប់ពីម៉ោង ៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែកក្កដា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក អ្នកស្រី និងនាងកញ្ញាជាអនុប្រធាន ទីប្រឹក្សា អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន ជំនួយការ អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ តាមបណ្តាញវីដេអូ កម្មវិធី Zoom សរុបប្រមាណ៨៣នាក់/គណនី។

គោលបំណងនៃកិច្ចប្រជុំដើម្បី:

- ធ្វើបច្ចុប្បន្នភាព សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីស្ថានភាពរាលដាល និង ការឆ្លើយតបនឹងមេរោគអេដស៍ ។
- ពិនិត្យ និងវាយតម្លៃពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គ ក្នុងការអនុវត្តផែនការសកម្មភាព និងផែនការបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអង្គប្រជុំ មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំ តាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញស្តីពីរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែកក្កដា និងទិសដៅការងារខែសីហា ឆ្នាំ២០២១ ដោយឯកឧត្តម ឈឹម ឃិនដារ៉ែត អគ្គលេខាធិការ

២) បទបង្ហាញស្តីពីគោលដៅឆ្នាំ២០២៥ ដោយឯកឧត្តម ទា ផលា អនុប្រធានទទួលបន្ទុកបច្ចេកទេស

៣) មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី

៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម **ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការធ្វើរបាយការណ៍ស្តីពីលទ្ធផលសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំខែកក្កដា ឆ្នាំ២០២១ និងលើកទិសដៅសម្រាប់ខែសីហា។

ដោយមានការអនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនជារ៉ែត** អគ្គលេខាធិការ បានធ្វើបទបង្ហាញដោយផ្តោតលើចំណុចសំខាន់ៗស្តីពីលទ្ធផលសកម្មភាពការងារដូចខាងក្រោម ៖

I- **បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន**

១- សកម្មភាពការងារដែលសម្រេចបាន ៖

- បានចូលរួមកិច្ចប្រជុំស្តីពីគម្រោងពង្រឹងសមត្ថភាពសហគមន៍ foNPAM and DfoNPAM របស់អង្គការ HACC
- តម្រង់ទិសការយល់ដឹងអំពីទស្សនទាន នៃការរៀបចំផែនការសកម្មភាព នៃការឆ្លើយតបមេរោគអេដស៍នៅខេត្តពន្លឿនការឆ្លើយតបមេរោគអេដស៍ ដោយ **ឯកឧត្តមអនុប្រធាន** ទទួលបន្ទុកបច្ចេកទេស។
- កិច្ចប្រជុំជាមួយក្រុមប្រជាជនគន្លឹះ ដឹកនាំដោយ **ឯកឧត្តម តែង គន្ធី**
- រៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋាន លើប្រធានបទ "ការបង្ហាញ និងបកស្រាយព័ត៌មាន" ដោយ **ឯកឧត្តម ហោ ប៊ុនឡេង**
- វគ្គបណ្តុះបណ្តាលមន្ត្រីអគ្គលេខាធិការដ្ឋានលើប្រធានបទ "ចំណេះដឹង និងជំនាញជាមូលដ្ឋានក្នុងការអនុវត្តវិធីសាស្ត្រវិទ្យាសាស្ត្រសរសេរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តផែនការ" ដោយ **ឯកឧត្តម ហោ ប៊ុនឡេង** ។
- សំណើសុំត្រៀមទូរថវិកាចំនួន៨០,០០០,០០០រៀល សម្រាប់អនុវត្តផែនការសកម្មភាពនិងឆ្លើយតបនឹងមេរោគអេដស៍ ខេត្តគោលដៅ *គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (FTC)

២- បញ្ហាប្រឈម ៖

- ការអូសបន្លាយនៃការរាតត្បាតមេរោគកូវីដ-១៩ នៅតែបន្តផលប៉ះពាល់ដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- ប្រព័ន្ធតាមដាន និងត្រួតពិនិត្យមិនទាន់មានលក្ខណៈបរិយាបន្ន និងមានភាពយឺតយ៉ាវ។
- បញ្ហាថវិកា DfoNPAM បានបង្រួមដៃនគ្រប់ដណ្តប់មកនៅត្រឹម៧ OD សម្រាប់ឆ្នាំ២០២១-២០២៣។

៣- ជំហានសម្រាប់ខែបន្ទាប់ ៖

- បន្តរៀបចំផែនការសកម្មភាព សូចនាករដៅ និងថវិកាសម្រាប់ខេត្តបាត់ដំបង
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៨។
- បន្តវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពការងារដល់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ។

II- **បទបង្ហាញ *ស្តីពីគោលដៅប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២៥ ដោយឯកឧត្តម*** **ជា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

- កិច្ចប្រជុំជាន់ខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីជំងឺអេដស៍ រួមបញ្ចូលនៅក្នុងយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺអេដស៍សកល ២០២១-២០២៦ ដែលអនុម័តដោយក្រុមប្រឹក្សាភិបាល UNAIDS។

- ការធ្វើបច្ចុប្បន្នភាពគោលដៅកម្មវិធីសម្រាប់ឆ្នាំ ២០២៥ ផ្តល់នូវចំណុចកណ្តាលនៅលើផ្លូវទៅកាន់ការបញ្ចប់ជំងឺអេដស៍ឆ្នាំ២០៣០។
- គោលដៅដែលទាក់ទងនឹងសេវា ៖ ៩៥% នៃប្រជាជនដែលប្រឈមនឹងការឆ្លងមេរោគអេដស៍បានប្រើប្រាស់សេវាបង្ការដែលផ្គុំគ្នា (Combination Prevention) ។
- យើងធ្លាប់ដឹងគោលដៅយុទ្ធសាស្ត្រ ៩៥-៩៥-៩៥ តែបើទេគឺ ៖
  ៩៥ទី១) ដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ ៩៥ទី២) បានធ្វើរោគវិនិច្ឆ័យ និងទទួលឱសថប្រឆាំង មេរោគអេដស៍ និង៩៥ទី៣) ទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងទទួលបាន ប្រសិទ្ធភាពខ្ពស់ក្នុងការកាត់បន្ថយចំនួនមេរោគអេដស៍ក្នុងខ្លួន។ ដូច្នេះយើងត្រូវបន្ថែមលើគោលដៅដែលមានស្រាប់ ប៉ុន្តែឥឡូវថែម៣ទៀត គឺគោលដៅដែលទាក់ទងនឹងសេវា ៖ ៩៥%ទី១) ប្រជាជនដែលប្រឈមនឹងការឆ្លងមេរោគអេដស៍បានប្រើប្រាស់សេវាបង្ការដែលផ្គុំគ្នា (Combination Prevention) ៩៥%ទី២) ស្ត្រីទទួលបានសេវាកម្មបន្តពូជនិងសុខភាពផ្លូវភេទ ៩៥%ទី៣) ការគ្របដណ្តប់សេវាកម្មសម្រាប់ការលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។
- បរិយាកាសគាំទ្រផ្លូវច្បាប់និងការទទួលបានសេវាកម្មយុត្តិធម៌ ៖ អ្នកផ្ទុកមេរោគអេដស៍ច្រើនជាង៩០% ដែលជួបប្រទះការរំលោភសិទ្ធិបានស្វែងរកដំណោះស្រាយនៅឆ្នាំ ២០២៥។
- សមភាពយេនឌ័រនិងរស់នៅដោយគ្មានអំពើហឹង្សា៖ ចំនួនប្រជាជនគន្លឹះសំខាន់ៗ និងស្ត្រីតិចជាង១០% ជួបប្រទះអំពើហឹង្សាលើរាងកាយ ឬផ្លូវភេទពីដៃគូជិតស្និទ្ធត្រឹមឆ្នាំ២០២៥។
- សង្គមដែលគ្មានការមាក់ងាយនិងរើសអើង ៖ អ្នកផ្ទុកមេរោគអេដស៍តិចជាង ១០% ជួបប្រទះការមាក់ងាយនិងការរើសអើងក្នុងការថែទាំសុខភាពនៅក្នុងសហគមន៍នៅឆ្នាំ ២០២៥។
- បន្តការពិភាក្សាជាមួយក្រុមការងារបច្ចេកទេស (Sub-Technical Working Groups) ពាក់ព័ន្ធ ដើម្បីស្រាយទិសដៅ និងបញ្ចូលគោលដៅពិភពលោក២០២៥ ក្នុងបរិបទនៃប្រទេសកម្ពុជា ព្រមទាំងរាយការណ៍ពីគោលដៅយុទ្ធសាស្ត្រ ពិនិត្យលើផែនការយុទ្ធសាស្ត្រដែលមានស្រាប់។
- យើងមានការលំបាកក្នុងករណីឆ្លងថ្មី បច្ចុប្បន្នមានការឆ្លង៣នាក់ក្នុងមួយថ្ងៃ ទូរលេខថ្មីរបស់យើងគឺ អ្នកផ្ទុកមេរោគអេដស៍តិច៧៥,០០០នាក់ ករណីឆ្លងថ្មីចំនួន១១០០នាក់ ករណីស្លាប់គឺចំនួន១២០០ និងអ្នកទទួលឱសថប្រឆាំងនឹងមេរោគអេដស៍ (ARV) ចំនួន៦២,៣១០នាក់ នេះជាទូរលេខបានប្រកាសជាផ្លូវការ។

III)- **មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី**

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- ក្នុងបរិបទនៃជំងឺកូវីដ-១៩ យើងមិនអាចចុះធ្វើការងារបាន តែយើងអាចធ្វើការងារបាននៅហ្នឹងកន្លែងតាមបណ្តាញប្រព័ន្ធអនឡាញ។ ថ្មីៗនេះមាន*វ៉ីរុសដែលតា* (Delta) បាននឹងកំពុងរាតត្បាតចូលក្នុងសហគមន៍ យើងត្រូវបន្តប្រុងប្រយ័ត្នខ្ពស់ ដោយត្រូវចេះផ្លាស់ប្តូរទម្លាប់រស់នៅរបស់ខ្លួនឱ្យស្របតាមពាក្យស្លោក "*រៀនរស់នៅជម្មតាជាមួយវ៉ីរុសកូវីដ-១៩ តាមបែបគន្លងថ្មី ក្នុងបរិបទប្រយុទ្ធនឹងជំងឺកូវីដ-១៩*"។ វាជាភ័ព្វសំណាងរបស់ប្រជាជនកម្ពុជាដែលបានចូលរួមចាក់វ៉ាក់សាំងបានច្រើន។

២- ចំនួនអ្នកឆ្លងថ្មីចំនួន ១,១០០ និងអ្នកស្លាប់១,២០០ក្នុងមួយឆ្នាំ ត្រូវធ្វើការសិក្សាបន្តទៅទៀតជាមួយ*អង្គការសហប្រជាជាតិប្រយុទ្ធនឹងជំងឺអេដស៍* (UNAIDS) និង*មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ* (NCHADS)។

៣- ត្រូវមានតួលេខក្នុងផ្នែកសុខាភិបាល និងផ្នែកមិនមែនសុខាភិបាល ដោយរៀបចំជាទិន្នន័យរបស់យើង។

៤- ចំពោះ*អត្តសញ្ញាណប័ណ្ណក្រីក្រ* (ID Poor) យើងបានធ្វើរួចហើយ ដោយគ្រួសារអ្នកផ្ទុកមេរោគអេដស៍ បានរៀបចំឈ្មោះនៅក្រសួងផែនការ បានទទួលជាសាច់ប្រាក់ឧត្ថម្ភពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ឯកឧត្តម **ឆា ថលា** ត្រូវដឹកនាំរៀបចំសរសេរគម្រោងសិក្សា (concept note)ជាមួយអនុប្រធានផ្សេងៗទៀត និងអគ្គលេខាធិការដ្ឋាន ដោយស្នើសុំមូលនិធិសកល (GF) ឱ្យជួយគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាល (NGOs) ឬអង្គការសង្គមស៊ីវិល (CSOs) ដោយសង្កត់ធ្ងន់លើការពង្រឹងប្រព័ន្ធជាតិ (strengthening country system) ដើម្បីមកធ្វើការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់។ រៀបចំ National data base មួយ ដែលមាន Health & non health information input (ID poor..,)។ ពេលឯកសារបានរៀបចប់សព្វគ្រប់ ឯកឧត្តមទេសរដ្ឋមន្ត្រីនឹងផ្ញើលិខិតជូនលោក **Mark Edington** និងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យមានការគាំទ្រ និងរក្សានូវនិរន្តរភាព។

៦- ឯកឧត្តម ឈឹម ឃិនដារ៉ែត ត្រូវបន្តរៀបចំកិច្ចប្រជុំជាមួយគណៈកម្មាធិការអេដស៍ក្រសួងមហាផ្ទៃ ដើម្បីឱ្យគាត់ណែនាំដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ស្រុក ខណ្ឌ និងឃុំ សង្កាត់គ្រប់រាជធានី ខេត្ត និងធ្វើផែនការថវិកា។ ជម្រុញការងារប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យល្អប្រសើរឡើង ពិសេសអំពី*គម្រោងទីក្រុងពន្លឿនការឆ្លើយតបនឹងជំងឺអេដស៍* (Fast Track City)។ ត្រូវទំនាក់ទំនងជាប្រចាំ ទី១) ស្នើសុំទៅមូលនិធិសកលឱ្យអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនឹង FoNPAM និងDfoNPAM ឱ្យមកធ្វើការសេវាគាំពារសង្គម ទី២) ត្រូវបន្តទំនាក់ទំនងជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីថវិកា៨០លានរៀល ផ្តល់ជូនទៅគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ប្រធានលេខាធិការដ្ឋាន (មិនមែនប្រធានមន្ទីរ) ដើម្បីមានថវិកាសម្រាប់ធ្វើការងារប្រយុទ្ធនឹងជំងឺអេដស៍ ទី៣) ត្រូវបន្តទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន រាជធានី/ខេត្ត ដោយណែនាំពីសកម្មភាពដែលគាត់ត្រូវតែធ្វើ ដូចជា*បុរសរួមភេទជាមួយបុរស* (MSM) និងធ្វើរបាយការណ៍មកឱ្យអ.ជ.ប.ជ.អទាន់ពេលវេលាក្នុងកិច្ចប្រជុំពេញអង្គលើកទី២ ដើម្បីទទួលបានការលើកទឹកចិត្ត និងប័ណ្ណសរសើរពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទី៤) យើងនៅមិនទាន់បានរៀបចំមជ្ឈមណ្ឌលព័ត៌មានស្តីពីវិធានការការពារ ការធ្វើតេស្តដោយខ្លួនឯង និងការចម្លងជំងឺអេដស៍នៅអ.ជ.ប.ជ.អ ដូច្នេះអគ្គលេខាធិការត្រូវពិភាក្សាជាមួយនាយកដ្ឋានហិរញ្ញវត្ថុ ដោយរៀបចំបណ្ណាល័យ បដា និងប៉ាណូសម្រាប់ផ្សព្វផ្សាយអំពីមេរោគអេដស៍ និងជំងឺអេដស៍។

៧- ផ្សព្វផ្សាយសេចក្តីសម្រេចចិត្តរបស់អ.ជ.ប.ជ.អ ឱ្យបានទូលំទូលាយតាម ហ្វេសប៊ុក (Facebook) និងតាមគេហទំព័រ (Website) បើមានស្ថិតិ (statistic) ជាភាសារអង់គ្លេស ត្រូវបកប្រែជាភាសារខ្មែរ។

៨- មុខសញ្ញាដែលចម្លងខ្លាំងនោះ គឺការរួមភេទរវាងបុរសជាមួយបុរស (MSM) ដែលមានហានិភ័យខ្ពស់នៃការឆ្លងជំងឺអេដស៍។ ត្រូវគិតគូជួបពិភាក្សាគ្នាជាមួយដៃគូគ្រប់លំដាប់ថ្នាក់។

៩- ចំពោះ *ស្ត្រីបម្រើសេវាកម្មាន្ត* (EW) បើពុំមានកើនឡើងនូវការឆ្លងថ្មីទេ ត្រូវរកវិធីបន្តទៀតទប់ស្កាត់ការចម្លងថ្មី និងត្រូវរៀបចំផែនការសកម្មភាពអាទិភាពឱ្យស្របគ្នានឹងគោលការណ៍នយោបាយយុទ្ធសាស្ត្រនីមួយៗ ក្នុងការឈានទៅរកភាពជោគជ័យនៃការប្រយុទ្ធនឹងជំងឺអេដស៍។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការងារឱ្យបានកាន់តែប្រសើរឡើង ដោយមានការឯកភាពគ្នាជាធ្លុងមួយ មានសាមគ្គីភាពផ្ទៃក្នុងល្អ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១: ០៥នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃអង្គារ ១០រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២១

បានឃើញ និងឯកភាព
ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

អៀង_មូលី

អ្នកធ្វើកំណត់ហេតុ

ស៊ីត_ចំចាន់